# ១៨- រឿង សំលាញ់ពីរនាក់

កាលពីព្រេងនាយ មានបុរសពីរនាក់ ជាសម្លាញ់នឹងគ្នា និយាយសន្យាគ្នាថា « កាលបើយើងមានប្រពន្ធហើយ ឯងក្តី អញក្តី បើមានទ្រព្យសម្បត្តិត្រូវយើងចិញ្ចឹមគ្នាទៅវិញទៅមក >> ។ សន្យាគ្នាហើយ យូរបន្តិចទៅសម្លាញ់មួយមានប្រពន្ធគ្រប់លក្ខណ៍ សម្លាញ់មួយទៀតមានប្រពន្ធខាតលក្ខណ៍ ។

វេលាយប់ចូលដំណេក សម្លាញ់ដែលមានប្រពន្ធគ្រប់លក្ខណ៍នោះ និយាយគិតគ្នាប្តីប្រពន្ធថា « យើងរកស៊ីអីឲ្យមានឆាប់ ?» ប្រពន្ធថា « អ្នកចង់រកស៊ីអី ឬប្រើខ្ញុំឲ្យត្បាញរវៃលក់ដូរ ខ្ញុំទទួលតាម មិនហ៊ានទទឹងទាស់ចិត្តអ្នកទេ» ។

លុះកន្លងមក ពេលចូលដំណេកយប់ក្រោយទៀត ប្តីនិយាយនឹងប្រពន្ធថា « នាងអើយបើគិតឃើញរបរមួយមុខ បើបានដូចគំនិតនឹងបានមាសប្រាក់ផ្តិល តុថាស ដោយងាយ» ។ ប្រពន្ធសួរប្តីថា « គិតធ្វើម្តេចក៏បានងាយម្ល៉េះ ? » ។ ប្តីប្រាប់ប្រពន្ធថា «ជាច្រើនឆ្នាំមកហើយនៅក្នុងសមុទ្រ មានសំពៅអ្នកជំនួញគ្រប់ប្រទេស ខ្លះសុខសប្បាយ ខ្លះលិចលង់របស់ទ្រព្យសព្វសារពើ មាសប្រាក់ កប់នៅបាតសមុទ្រនោះច្រើន យើងគិតនាំគ្នាទៅបាចទឹកសមុទ្រនោះឲ្យរីង ក្រអ្វី មាសប្រាក់ របស់គ្រប់មុខនោះ, បើបានត្រីធំតូចយើងធ្វើងៀត ធ្វើផ្អកប្រហុក, ព្រឹកព្រហាមស្រាងនេះ នាងឯងដាំបាយដួសដាក់កញ្ជើ ឲ្យមានម្ហូបនិងស្លាម្លូផង យើងទៅបាចទឹកសមុទ្រឲ្យរីង » ។ ប្រពន្ធឮប្តីប្រាប់ហើយ ក៏ធ្វើតាមបង្គាប់ ។ លុះព្រឹកឡើង រៀបគ្រប់ប្រដាប់រួចក៏នាំទៅមាត់សមុទ្រ ហើយទុកដាក់បាយម្ហូបចំណីដោយស្រួល ទើបប្តីកាន់កញ្ជើ ១ ខំបាចទឹកទៅលើគោក បាចទាល់តែដល់ពេលបាយ ទើបឈប់បរិភោគ លុះបរិភោគបាយរួច នាំប្តីប្រពន្ធបាចទៀតដល់ល្ងាចទើបទៅផ្ទះ, ព្រឹកឡើងនាំគ្នាទៅបាចទៀតទាល់ល្ងាច ទើបនាំគ្នាមកផ្ទះវិញ ។ បាចបានចំនួន ៥ ថ្ងៃ ប្តីក៏ឈរបាំងដៃមើលទឹកសមុទ្រ ហើយប្រាប់ប្រពន្ធថា «ទឹកស្រកសណ្តកហើយនាង » ។ ប្រពន្ធឆ្លើយថា «បើដូច្នោះ យើងខំបាចទៅ បើយូរណាស់ត្រឹមកន្លះខែទៀតមុខជារីងហើយ យើងចាប់យកត្រីធំតូចវះធ្វើងៀតផ្អកប្រហុកថ្លឹងលក់យកប្រាក់, មួយទៀត យើងត្រូវរកកាយយកប្រាក់មាស តុ ថាស ចានក្បាន ដ៏មាននៅក្នុងសំពៅទាំងប៉ុន្មាន ដែលលិចលង់មកយូរឆ្នាំនោះ មិនដឹងបើយកទៅណាអស់ទេ» ថាហើយដល់ល្ងាចនាំគ្នាត្រឡប់មកផ្ទះវិញ ។ ព្រឹកឡើងនាំគ្នាទៅបាចទៀត ហើយនិយាយតែពាក្យដដែលៗដូចថ្ងៃមុន ។ ហ្វូងមច្ឆាក្នុងសមុទ្រស្តាប់ឮដឹងដំណើរសព្វគ្រប់ ភ័យបារម្ភណាស់ជំនុំគ្នាថា «យើងមុខជាស្លាប់ម្តងនឹងហើយ គួរតែយើងនាំគ្នាទៅទូលស្តេចត្រីអន្ទ្យាសមុទ្រទើបរស់ជីវិត » គិតហើយនាំគ្នាមុជហែលទៅដល់ស្តេចត្រី ទូលតាមដំណើរ ដែលបុរសប្តីប្រពន្ធមកបាចទឹកសមុទ្រនោះ ។ ស្តេចត្រីដឹងហើយបង្គាប់ត្រីទាំងប៉ុន្មានដែលទៅទូលនោះថា «ឯងរាល់គ្នាពាំយកមាស ៥ ក្រឡ ប្រាក់ ៥ ក្រឡ និងតុ ថាសផ្តិល ចានទៅឲ្យបុរសប្តីប្រពន្ធ អង្វរគេឲ្យលែងបាចទឹកសមុទ្រទៅ » ត្រីទាំងនោះក៏យកវត្ថុគ្រប់ចំនួនតាមស្តេចត្រីបង្គាប់ រួចនាំគ្នាពាំហែលមកដល់បុរសប្តីប្រពន្ធ អង្វរសូមឲ្យលែងបាចទឹកសមុទ្រ ត្រីទាំងនោះក៏ហាមាត់ខ្ជាក់ក្រឡមាសប្រាក់ តុថាសផ្តិល ចានឲ្យបុរសប្តីប្រពន្ធ ។ បុរសប្តីប្រពន្ធ មានសេចក្តីត្រេកអរពន់ពេក ក៏ឈប់លែងបាចទឹកពីថ្ងៃនោះ នាំប្តីប្រពន្ធរែកទូលជញ្ជូនទៅទុកផ្ទះត្រាតែអស់ ។ បុរសប្តីប្រពន្ធក៏មានទ្រព្យសម្បត្តិច្រើនថ្កើងរុងរឿង បានសេចក្តីសុខរៀងទៅ ។

ពណ៌នាពីសម្លាញ់ដែលមានប្រពន្ធខាតលក្ខណ៍ គាត់ភ្នកនឹករឭកដល់សំឡាញ់ ហើយនាំប្រពន្ធទៅលេងផ្ទះសំឡាញ់ ដែលមានប្រពន្ធគ្រប់លក្ខណ៍, លុះឡើងដល់លើផ្ទះ ឃើញគេនៅរាប់អានចាំចិត្តស្និទ្ធស្នាលដូចពីដើម, គាត់គន់មើលរបស់ទ្រព្យប្រដាប់ប្រដាក្នុងផ្ទះគេ ហើយនឹកក្នុងចិត្តថា «ពីដើម សំឡាញ់គេមានទ្រព្យសម្បត្តិល្មមគួរសមទេ ឥឡូវនេះគេរករបរអ្វី ក៏មានទ្រព្យសម្បត្តិច្រើនម្ល៉េះ» គិតហើយត្អូញប្រាប់សម្លាញ់ដែលមានទ្រព្យសម្បត្តិថា « សំឡាញ់អើយ ! អញសព្វថ្ងៃនេះក្រលំបាកណាស់, ចុះសម្លាញ់ឯងរកស៊ីជំនួញអ្វី , ក៏មានទ្រព្យសម្បត្តិច្រើនម្ល៉េះ » ។ សម្លាញ់ដែលមានប្រពន្ធគ្រប់លក្ខណ៍ថា «សំឡាញ់អើយ ! អញរកស៊ីបាចទឹកសមុទ្រតែពីរនាក់នឹងប្រពន្ធអញ, ពេលព្រឹកទៀបភ្លឺប្រពន្ធអញដាំបាយគ្រប់ប្រដាប់ លុះភ្លឺឡើង នាំគ្នាទៅបាចទឹកសមុទ្រ, ល្ងាចត្រឡប់មកផ្ទះវិញ ស្ដេចត្រីភ័យបង្គាប់ត្រីជាបរិវារឲ្យពាំមាសប្រាក់ នឹងរបស់គ្រប់មុខឲ្យអញ » ។

ឯសំឡាញ់ មានប្រពន្ធខាតលក្ខណ៍ដឹងហើយ ក៏លាសំឡាញ់ដែលមានប្រពន្ធគ្រប់លក្ខណ៍ ។ គេក៏ឲ្យប្រាក់យកទៅចិញ្ចឹមជីវិត ។ លុះត្រឡប់ទៅផ្ទះវិញ ពេលចូលដំណេក បុរសនោះនិយាយនឹងប្រពន្ធថា « ព្រឹកនេះឯងដាំបាយពីយប់រៀបប្រដាប់ឲ្យមានសព្វគ្រប់, ភ្លឺឡើងយើងនឹងនាំគ្នាទៅបាចទឹកសមុទ្រ ឲ្យបានមាសប្រាក់របស់ទ្រព្យដូចសំឡាញ់យើង ។ លុះភ្លឺច្បាស់ មេខាតលក្ខណ៍ជាប្រពន្ធ បានក្រោកបង្កាត់ភ្លើងឆេះហើយ បានបើកខាប់វាល់អង្ករ ៗ កំពប់ម្ដងមួយទូកដៃ យកអង្ករទៅលាងកំពប់មួយទូកដៃទៀត ច្រកអង្ករទៅក្នុងឆ្នាំងកំពប់ទៀតដល់ពុះជាត់បាយកំពប់ទៀត ច្រកអង្ករចំនួនល្មមឆ្អិនពេញឆ្នាំង បាយនៅតែកន្លះឆ្នាំង, ទាល់តែថ្ងៃណាស់ហើយ ទើបដួសដាក់កញ្ជើហើយបណ្ដើរប្ដីប្រពន្ធទៅបាចទឹកសមុទ្រ បាចទាំងខឹងទាំងជា ។ បាចចំនួន ៥ ថ្ងៃ អស់ហ្វូងមច្ឆាតូចធំ ផ្អើលភិតភ័យនិយាយគ្នាថា « បុរសប្ដីប្រពន្ធពីណា មកបាចទឹកសមុទ្រទៀតហើយ» ពួកត្រីក៏សម្លឹងទាំងហ្វូងចាំមើលចាំស្ដាប់ ។ ប្រពន្ធខាតលក្ខណ៍បោកល្អីដែលបាចទឹកនោះ ហើយថា «បាចយូរថ្ងៃហើយមិនបានឃើញរបស់អ្វី អញមិនខ្វីទេ អញលែងបាចហើយ» ឈ្លោះប្ដីប្រពន្ធជេរម្ដាយប្ដី ប្ដីបញ្ចោរប្រពន្ធ ប្រកាច់ចំបាប់គ្នា ប្រទាញសំពត់គ្នាទៅវិញទៅមក ទាល់តែអាស្រាតទាំងប្ដីទាំងប្រពន្ធ លេចកេរ្តិ៍ខ្មាសនៅមាត់សមុទ្រ ហើយអ្នកទាំងពីរនាក់ថា « ខ្ញុំគេក៏ខ្ញុំចុះ លែងបាចហើយ » ។ ត្រីទាំងនោះឮថាលែងបាចក៏ត្រេកអរធូរចិត្ត លែងសូកឲ្យមាសប្រាក់របស់ទាំងពួង ។ ត្រីទាំងនោះបានឃើញកេរ្តិ៍ខ្មាសបុរសប្ដីប្រពន្ធ ក៏លោតសើចទាំងហ្វូង ។ ឯត្រីសណ្ដាយសើចទាល់តែរយះមាត់ បានជាមាត់ធំដូចគេហែក រហូតដល់បច្ចុប្បន្ននេះ ។

បុរសប្ដីប្រពន្ធគ្មានបានអ្វីសោះ ក៏លែងឈ្លោះគ្នា នាំគ្នាដកសារាយ ។ ប្ដីមួយអម្រែក, ប្រពន្ធមួយទ្រនូល ត្រឡប់មកផ្ទះវិញ ចាក់សារាយចោលនៅកៀនជញ្ជាំង ឲ្យរលួយខូចអស់ទៅ ។

**នាងរត់រកអ្នក មេខាតលក្ខណ៍ រត់រកអាបាក់ទន្សា។**